# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ....៤៣.....សសរ

## សេចក្ដីសំរេច
### ស្ដីពី
### ការកែសំរួលសមាសភាពគណៈកម្មាធិការចំរុះអចិន្ត្រៃយ៍ ការងារទំនប់ ប្រឡាយនៅតំបន់ព្រំដែន កម្ពុជា_វៀតណាម_ឡាវ_ថៃ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម

-បានឃើញសេចក្ដីសំរេចលេខ ០៨ សសរ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២ ស្ដីពីការបង្កើត គណៈកម្មាធិការចំរុះអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ ប្រឡាយនៅតំបន់ព្រំដែន កម្ពុជា-វៀតណាម-ឡាវ-ថៃ

-យោងតាមតំរូវការចាំបាច់

## ស ំ រ េ ច

**ប្រការ ១ .-**

កែសំរួលសមាសភាពប្រការ១ នៃសេចក្ដីសំរេចលេខ ០៨ សសរ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០០២ ស្ដីពីការបង្កើតគណៈកម្មាធិការចំរុះអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ប្រឡាយ នៅតំបន់ព្រំដែនកម្ពុជា-វៀតណាម-ឡាវ-ថៃ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ម៉ិន ម៉ៅន អគ្គនាយកកិច្ចការបច្ចេកទេស នៃក្រសួងធនធានទឹក និងឧតុនិយម ប្រធាន

២-លោក ហួន សាវ៉ាង អគ្គនាយករងនៃអគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងជាតំណាងគណៈកម្មាធិការចំរុះកិច្ចការព្រំដែន អនុប្រធាន
៣-លោក កែវ ឥន្ទី អនុប្រធាននាយកដ្ឋានច្បាប់-កុងស៊ុលនៃក្រសួងការបរទេសនិងសហប្រតិបត្តិអន្តរជាតិ អនុប្រធាន
៤-លោក គីង ភារុទ្ធិ នាយកនៃនាយកដ្ឋានផ្លូវទឹកនៃក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក
៥-លោក ហួយ គីមឡុនៈ ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅនៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ សមាជិក
៦-លោក ម៉ឹន ណារិន្ទ ប្រធាននាយកដ្ឋានវារីអគ្គិសនីនៃក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សមាជិក
៧-ឯកឧត្តម ពេជ ខុន អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក
៨-លោក មាស សុផល អនុប្រធាននាយកដ្ឋានការពារនិងអភិរក្សធនធានធម្មជាតិនៃក្រសួងបរិស្ថាន សមាជិក
៩-លោក គិត សេង ប្រធាននាយកដ្ឋានផែនការ-ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ សមាជិក
១០-លោក គល់ វណ្ណនា អនុប្រធាននាយកដ្ឋានការពារ និងអភិរក្សធនធានធម្មជាតិនៃក្រសួងបរិស្ថាន សមាជិក
១១-លោក នូ នឹម នាយអគ្គលេខាធិការដ្ឋានសាលាខេត្តកណ្តាល សមាជិក
១២-លោក ស៊ុយ ស៊ីថុន ប្រធានការិយាល័យធារាសាស្ត្រនៃនាយកដ្ឋានកសិកម្មនៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

**ប្រការ ២ .-**

ប្រការដទៃទៀតនៃសេចក្តីសំរេចលេខ ០៨ សសរ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបង្កើតគណៈកម្មាធិការចំរុះអចិន្ត្រៃយ៍សំរបសំរួលការងារទំនប់ ប្រឡាយនៅតំបន់ព្រំដែនកម្ពុជា-វៀតណាម-ឡាវ-ថៃត្រូវរក្សាទុកជាធរមានដដែល ។

**ប្រការ ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន និង សាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ដែលមានការពាក់ព័ន្ធត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១
- ឯកសារ-កាលប្បវត្តិ.